# តើជំរឿននៅឆ្នាំ 2020 នឹងសួរខ្ញុំពីធ្វីខ្លះ?

NORTH CAROLINA
ASIAN AMERICANS TOGETHER

*www.ncaatogether.org/census*

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ ផ្នែកជំរឿនរបស់យើងតាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ www.CountUsIn2020.org/hotline សម្រាប់ព័ត៌មានបន្ថែម។*

ជំរឿនចាប់ផ្ដើមឡើងនៅខែមីនា ឆ្នាំ 2020! ការឆ្លើយតបទៅនឹងជំរឿននឹងធានាថាគ្រួសារ និង សហគមន៍របស់អ្នកទទួលបានចំណែកយុត្តធម៌នៃធនធានរដ្ឋាភិបាល សេវាកម្ម និង អ្នកតំណាងរបស់ខ្លួន។ ចាប់ផ្ដើមនៅក្នុងពាក់កណ្ដាលខែមីនា ឆ្នាំ 2020 អ្នកអាចឆ្លើយតបទៅនឹងជំរឿននៅលើបណ្ដាញអ៊ីនធឺណែត តាមរយៈទូរស័ព្ទ ឬតាមរយៈបញ្ញើប្រៃសណីយ៍។ គ្រួសារនីមួយៗ (គ្រួសារមួយរាប់បញ្ចូលសមាជិកទាំងអស់ដែលរស់នៅក្នុងអាស័យដ្ឋានតែមួយ) គួរដាក់ស្នើទម្រង់បែបបទមួយច្បាប់ ហើយគួរចុះបញ្ជីមនុស្សគ្រប់រូបដែលរស់នៅអាស័យដ្ឋាននោះ។

## ជំរឿនឆ្នាំ2020 នឹងសួរអំពីគ្រួសាររបស់អ្នក៖

| | |
|---|---|
| **ចំនួនសមាជិកក្នុងគ្រួសារនៅថ្ងៃទី1 ខែមេសា។** | *រួមបញ្ចូលសមាជិកគ្រប់គ្នាដែលរស់នៅក្នុងផ្ទះរបស់អ្នក ថ្វីបើពួកគេពុំជាប់ជាសាច់ឈាមជាមួយនឹងអ្នកក្ដី។ ការធ្វើជំរឿនរាប់ មនុស្សទាំងអស់នៅសហរដ្ឋអាមេរិក រួមទាំងកុមារតូចៗ ប្រជាពលរដ្ឋដែលមិនទាន់ចូលសញ្ជាតិ អ្នកជួល - គ្រប់គ្នា។* |
| **តើអ្នកមានផ្ទះខ្លួនឯង ឬ ជួលផ្ទះគេ?** | |
| **លេខទូរស័ព្ទ** | *នឹងប្រើប្រាស់តែក្នុងករណីចាំបាច់សម្រាប់អាជីវកម្មរបស់ការិយាល័យជំរឿនផ្លូវការប៉ុណ្ណោះ។* |

## ជំរឿនឆ្នាំ2020 នឹងសួរអំពីសមាជិកដែលរស់នៅក្នុងគ្រួសាររបស់អ្នក។

| | |
|---|---|
| **ឈ្មោះ ភេទ អាយុ និង ថ្ងៃខែឆ្នាំកំណើត របស់បុគ្គលម្នាក់ៗនៅក្នុងគ្រួសារ** | |
| **ទំនាក់ទំនងជាមួយបុគ្គលដែលបំពេញសំណុំបែបបទ** | |
| **ពូជសាសន៍** | *អ្នកអាចជ្រើសរើស ពូជសាសន៍មួយ ឬ ច្រើន។ ប្រសិនបើអ្នកជាកូនកាត់ច្រើនសាសន៍ អ្នកអាចជ្រើសរើសប្រអប់មួយ ឬ ច្រើនសម្រាប់ក្រុមជាតិសាសន៍របស់អ្នក ហើយសរសេរព័ត៌មានបន្ថែមអំពីប្រវត្តិនៃជាតិសាសន៍របស់អ្នក។*<br><br>*មិនមានគ្រប់ជាតិសាសន៍ទាំងអស់សុទ្ធតែត្រូវបានរាយបញ្ជីសម្រាប់អោយជ្រើសរើសឡើយ។ ប្រសិនបើក្រុមជាតិសាសន៍របស់ អ្នកមិនមានក្នុងបញ្ជីទេ អ្នកអាចសរសេរលម្អិតបន្ថែមអំពី ប្រវត្តិ នៃជាតិសាសន៍របស់អ្នកបាន។* |
| **ជនជាតិដើមអេស្ប៉ាញ** | *ប្រភពដើមជនជាតិអេស្ប៉ាញត្រូវបានចាត់ទុកជាជាតិសាសន៍ មិនមែនពូជសាសន៍ទេ។ អ្នកអាចកត់សម្គាល់ថាអ្នកមិនមែនជា ជនជាតិដើមអេស្ប៉ាញ ឬសម្គាល់ថាអ្នកជាជនជាតិដើមអេស្ប៉ាញ ហើយសម្គាល់ពីប្រភពជាតិសាសន៍ដើមរបស់អ្នក។* |

ទម្រង់បែបបទនឹងមិនសួរអ្នកអំពីអន្តោប្រវេសន៍ឬស្ថានភាពនៃភាពជាប្រជាជនរបស់អ្នកឡើយ។

ទម្រង់បែបបទនឹង*មិន*សួររកលេខសន្តិសុខសង្គម (SSN) របស់អ្នកទេ។

## តើការចូលរួមក្នុងជំរឿនមានសុវត្ថិភាពឬទេ?

ចម្លើយជំរឿនរបស់អ្នកគឺជាការសម្ងាត់។ ការិយាល័យជំរឿនមិនត្រូវបានអនុញ្ញាតឱ្យចែកចាយ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយ ភ្នាក់ងាររដ្ឋាភិបាល មន្ត្រីអន្តោប្រវេសន៍ ឬ សាធារណជនណាឡើយ។

ច្បាប់សហព័ន្ធតម្រូវឱ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមក្នុងជំរឿន ហើយឆ្លើយគ្រប់សំណួរទាំងអស់ ដោយភាពស្មោះត្រង់។ កុំព្យាយាមកុហកពេលឆ្លើយតបទៅនឹងជំរឿន។ ប្រសិនបើអ្នករំលង សំណួរណាមួយ ទម្រង់បែបបទរបស់អ្នកនឹងនៅតែត្រូវបានរាប់បញ្ចូល។ ឆ្លើយតបនឹងជំរឿនអោយបានពេញលេញតាមដែលអាចធ្វើបាន នឹងជួយធានាថាអ្នកប្រមូលទិន្នន័យជំរឿននឹងមិនចុះទៅតាមផ្ទះរបស់អ្នកដើម្បីសាកសួរព័ត៌មានបន្ថែមដែលនូវខ្វះខាត។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ* [www.CountUsIn2020.org/resources](http://www.CountUsIn2020.org/resources)។